**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២០)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១២ ៤៤៥នាក់ នៃរោងចក្រ សហគ្រាស ទាំង៧៩ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទី១ស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) របស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) នេះ នឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៤០ ៥០០រៀល (១០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ៨១ ០០០រៀល (២០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ៣០ថ្ងៃ
- ២០២ ៥០០រៀល (៥០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៣១ថ្ងៃ ដល់ ៤៩ថ្ងៃ
- ២៤៣ ០០០រៀល (៦០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៥០ថ្ងៃ ដល់ ២ខែ។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីង ដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៧៩ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ១១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៧៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល លើកទី២ (លើកបញ្ចប់)**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (លើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 44 |
| 1 | ក្រុមហ៊ុនជីឌីអិម អ៊ិនធើប្រាយ | ភ្នំពេញ |
| 2 | ក្រុមហ៊ុនស៊ីនចាង ថេក អ៊ីន | ភ្នំពេញ |
| 3 | ក្រុមហ៊ុនឈាន ឈុន ហ្វុង ជា ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុនហុង ជា (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុនសាន់ វ៉ាន់ (ខេមបូឌា) ហ្គាម៉ិន | ភ្នំពេញ |
| 6 | ក្រុមហ៊ុនខូហ៊ីស្គ(ខេមបូឌា) | ភ្នំពេញ |
| 7 | ក្រុមហ៊ុនស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុនស៊ីន ស៊ី អេក អិន ហុង(ខេមបូឌា)ប្លាស្ទិក អ៊ិនដាស្ទ្រី | ភ្នំពេញ |
| 9 | ក្រុមហ៊ុនធី&ខេ ហ្គាមេន អ៊ីនដាស្ទ្រី | ភ្នំពេញ |
| 10 | ក្រុមហ៊ុនប៊ុលតិច អ៊ិនដាសស្ទ្រីល (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 11 | ក្រុមហ៊ុនហ្វូតាហ្វីតវែរ ឯ.ក | ភ្នំពេញ |
| 12 | ក្រុមហ៊ុនហាយ សេង 168(ខេមបូឌា)ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុនឈុនឌីង ព្រីនធីង ខូអិលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុនធី អ័រ ស៊ី អេ ហ្គាម៉ិន | ភ្នំពេញ |
| 15 | ក្រុមហ៊ុនយៃនធើរេន អីកែវីល (ខេមបូឌា) | ភ្នំពេញ |
| 16 | ក្រុមហ៊ុនម៉នីងគ្លរី ហ្គាមេន អេនធើប្រាយ | ភ្នំពេញ |
| 17 | ក្រុមហ៊ុនវ៉ាយ អិម ជី ហ្គាមេន អេកសេសើរី | កណ្ដាល |
| 18 | ក្រុមហ៊ុន អេសអ៊ីអ៊ីអេស គ្លូបល(ខេមបូឌា)ខូ អិលធីឌី | កណ្ដាល |
| 19 | ក្រុមហ៊ុនហ៊ាំង ឌាន មេធៀរៀល ឯ.ក | កណ្ដាល |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុនហឺង ផេំ លេឌើរវែរ(ខេមបូឌា)ហ្វេកធើរី | កណ្ដាល |
| 21 | ក្រុមហ៊ុនដា វ៉ុង ព្រីនធីង & អឹមប្រយឌើរី | កណ្ដាល |
| 22 | ក្រុមហ៊ុនស្តារីត (ខេមបូឌា) ឯ.ក | កណ្ដាល |
| 23 | ក្រុមហ៊ុនថៃ យ៉ា ហ្គាមេន អ៊ិនដាសស្ទ្រី | កណ្ដាល |
| 24 | ក្រុមហ៊ុនរីជេន ហ្វ៊ូតវែរ (ខេមបូឌា) ខូ អិលធីឌី | កណ្ដាល |
| 25 | ក្រុមហ៊ុនតុងឆាយ | កណ្ដាល |
| 26 | ក្រុមហ៊ុនភើហ្វម វែល ហូលឌីង (ខេមបូឌា) លីមីធីត | កណ្ដាល |
| 27 | ក្រុមហ៊ុនបូរឃើ ហ្គាមេន ព្រីនធីង(ខេមបូឌា)ខមភេនី លីមីធីត | កណ្ដាល |
| 28 | ក្រុមហ៊ុន ហុន ធីហ្វ៊ី ហ៊្វុង (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 29 | ក្រុមហ៊ុន ហេង ស៊ុម ហ៊្វូត វែរ ឯ.ក | កំពង់ស្ពឺ |
| 30 | ក្រុមហ៊ុនស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 31 | ក្រុមហ៊ុនហ៊ីប គីង (ខេមបូឌា)មេនូហ្វេកឆឺរីង ឯ.ក | កំពង់ស្ពឺ |
| 32 | ក្រុមហ៊ុនហ៉រសេងដារ ហ្វ៊ីបភើ (ខេម) | កំពង់ស្ពឺ |
| 33 | ក្រុមហ៊ុនញូអេធីធី ស៊ូ ម៉េកឃីង (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 34 | ក្រុមហ៊ុនហៃនឋុន ឡាក់ហ្គេត (ខេមបូឌា) ឯ ក | កំពង់ស្ពឺ |
| 35 | ក្រុមហ៊ុនហ៊្វយ រួយ ស៊ីន ហៃនបើក (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 36 | ក្រុមហ៊ុនហុងកុងវីនហ្វៀរហ្គាមេន(ខេមបូឌា)អិលធីឌី | កំពង់ស្ពឺ |
| 37 | ក្រុមហ៊ុនចេនតៃ-យូឆាង (ខេអេចអិម) វ៉ូវេនថេប អ៊ិនធើប្រាយ ខូ អិលធីឌី | កំពង់ស្ពឺ |
| 38 | ក្រុមហ៊ុនស្រ្តង ហែលធ៍ អ៊ិនធើណេសិនណល លីមីធីត | តាកែវ |
| 39 | ក្រុមហ៊ុនខតចិនខនសិប អ៊ិនដាសស្ទ្រី ឯ.ក | តាកែវ |
| 40 | ក្រុមហ៊ុនណាញ ស្កាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 41 | ក្រុមហ៊ុនអ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 42 | ក្រុមហ៊ុនតូកូកូសេន ហ្គាមេន (ខេមបូឌា) | ស្វាយរៀង |
| 43 | ក្រុមហ៊ុនវ៉ាន់ធីជ វីវើរ ថេកស្តាយ | ព្រះសីហនុ |
| 44 | ក្រុមហ៊ុនជីនចេនយ៉ន(ខេមបូឌា) | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 35 |
| 45 | ក្រុមហ៊ុន សិប្បករអង្គរ | ភ្នំពេញ |
| 46 | ក្រុមហ៊ុនទេសចរណ៍រើលដ៏អិចប្រេស | ភ្នំពេញ |
| 47 | ក្រុមហ៊ុនវីណា ហុងកុង ខំផេនី អែលធីឌី | ភ្នំពេញ |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សណ្ឋាគារ ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| 48 | ក្រុមហ៊ុនណាហ្គាវើលដ៍ លីមីធីត | ភ្នំពេញ |
| 49 | ក្រុមហ៊ុន ឥណ្ឌូឆាយណា សឺវីសស៍ (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 50 | ក្រុមហ៊ុនញូយ៉ក ហូថេល & សឺវីសអីផាតមិុន | ភ្នំពេញ |
| 51 | ក្រុមហ៊ុនម៉ាស្ទ័រស៊ុតឌីស៊ុប | ភ្នំពេញ |
| 52 | ក្រុមហ៊ុន៥ អូសិន ឌូអិលធីឌី | ភ្នំពេញ |
| 53 | ក្រុមហ៊ុនស៊ីវ៉ាយ-អេសអេ ហូថេល ហ្វ្រេន ឡាយអិន ឯ.ក | សៀមរាប |
| 54 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 55 | ក្រុមហ៊ុនសិប្បករអង្គរ | សៀមរាប |
| 56 | ក្រុមហ៊ុនអង្គរ ហូលីដេ | សៀមរាប |
| 57 | ក្រុមហ៊ុនឡូទុស ប្លង្គ រីសត | សៀមរាប |
| 58 | សណ្ឋាគារវិក្ទូរីយ៉ាអង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 59 | សណ្ឋាគារដឺឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 60 | ក្រុមហ៊ុន ឥណ្ឌូឆាយណា ស៊ីវីសស៍ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 61 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 62 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 63 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 64 | ក្រុមហ៊ុន ដឺ ប្លែក សាន់ រេសចឺរេន អេន បារ ខូ អិលធីឌី | សៀមរាប |
| 65 | ក្រុមហ៊ុនអានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 66 | ក្រុមហ៊ុនសារ៉ៃរីសត និង ស្ប៉ា | សៀមរាប |
| 67 | ក្រុមហ៊ុនត្រេហ្ស៊ី អូអេស៊ីស | សៀមរាប |
| 68 | ក្រុមហ៊ុនឌីណាតា អង្គរ | សៀមរាប |
| 69 | ក្រុមហ៊ុនលីនរតនៈអង្គរ | សៀមរាប |
| 70 | សណ្ឋាគារ អង្គរ | សៀមរាប |
| 71 | ក្រុមហ៊ុនដឺ អេវៀរី | សៀមរាប |
| 72 | ក្រុមហ៊ុនអេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 73 | ក្រុមហ៊ុនប៉ូរ ឃ្វីហ្ស៊ីន | សៀមរាប |
| 74 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 75 | ក្រុមហ៊ុនមុទិតា រីសត & ស្ប៉ា | សៀមរាប |
| 76 | ក្រុមហ៊ុនឡាយ ហ្គូលយ៉ាណា អង្គរ ហូថេល ឯ.ក | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| 77 | ក្រុមហ៊ុនហាទៀន វីហ្គាស អេនធើធេនមេន រីហ្សត | កំពត |
| 78 | សណ្ឋាគារ ឋានសួគ៌សុខា | កំពត |
| 79 | ក្រុមហ៊ុនរមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |